# Home ព័ត៌មានជាតិ  វៀតណាម ចាប់ស្រ្តីខ្មែរពពោះជំនួសចិន៣នាក់ បញ្ជូនមកកម្ពុជាវិញ



## វៀតណាម ចាប់ស្រ្តីខ្មែរពពោះជំនួសចិន៣នាក់ បញ្ជូនមកកម្ពុជាវិញ

---

16/7/2019 5:34 PMព័ត៌មានជាតិ, សន្តិសុខ និងសង្គម

ភ្នំពេញ ៖ ស្រ្តីខ្មែរ៣នាក់ដែលពាក់ព័ន្ធបទល្មើសពពោះជំនួស ត្រូវបាននគរបាលវៀតណាមចាប់បញ្ជូនមកអោយនគរបាលកម្ពុជាវិញ បន្ទាប់ពីពួកគេឆ្លងដែនទៅសម្រាលកូននៅក្បែរព្រំដែនវៀតណាម ចិន។ សំណុំរឿងក្តីនេះ ត្រូវបាននគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃបញ្ជូនមកកាន់សាលាដំបូងរាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី ១៦កក្កដា ឆ្នាំ២០១៩នេះដើម្បីធ្វើការសាកសួរ។ លោកគុជ គឹមឡុង អ្នកនាំពាក្យអយ្យការអមសាលាដំបូងបានអោយដឹងថា ជនសង្ស័យដែលសមត្ថកិច្ចបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមានឈ្មោះ ១/ សេង ចិន្តា ហៅដា អាយុ៣២ឆ្នាំ មានទីលំនៅភូមិគោល ឃុំទួលពេជ្រ ស្រុកអង្គស្នួល ខេត្តកណ្តាល។ ២/ ឈ្មោះ ភួន ស៊ីនឿន អាយុ៣២ឆ្នាំ មានទីលំនៅភូមិឃុំជាមួយគ្នា។ ៣/ ឈ្មោះ សាត សារួន អាយុ៣១ឆ្នាំ។ ពាក់ព័ន្ធករណីពពោះជំនួសខាងលើនេះ បើតាមចម្លើយរបស់ឈ្មោះ សេង ចិន្តា បានអោយដឹងថា នៅក្នុងខែតុលា ឆ្នាំ២០១៨ នាងបានទៅផ្ទះរបស់ឈ្មោះ ភួន ស៊ីនឿន ដែលនៅក្នុងភូមិជាមួយគ្នានិយាយបញ្ចុះបញ្ចូលអោយទៅពរពោះជំនួសជនជាតិចិននៅភ្នំពេញ ដោយទទួលបានប្រាក់ចំនួន៨ ០០០ ដុល្លារក្នុងទារកមួយ ។ ក្រោយមកនៅថ្ងៃទី ១១តុលា ឆ្នាំ២០១៨ ឈ្មោះភួន ស៊ីនឿន បានមកភ្នំពេញតាមការរៀបចំរបស់សេង ចិន្តា ដោយបានជួបបុរស ស្រ្តីជនជាតិចិន៧នាក់ ហើយការនិយាយគ្នាគឺមានអ្នកបកប្រែភាសាចិន។ លុះដល់ថ្ងៃទី ២៥តុលា ២០១៨ មានក្រុមគ្រូពេទ្យចិនបានពិនិត្យប្រដាប់បន្តពូជ ហើយក៏ដាក់បញ្ចូលមេជីវិតទៅក្នុងស្បូន ហើយពួកគេក៏អោយលុយកាក់មួយចំនួនសម្រាប់ហូបចុក ថែរក្សាសុខភាព និងពិនិត្យគភ៌ ក្រោយមកខ្លួនបានប្រាប់ថានាងមានផ្ទៃពោះហើយ ពេលនោះនៅថ្ងៃទី ១២មិថុនា ឆ្នាំ២០១៩ ពួកចិនបានអោយនាងឡើងមកភ្នំពេញដើម្បីធ្វើលិខិតឆ្លងដែន ហើយគេក៏អោយប្រាក់នាងថែម២ ០០០ ដុល្លារទៀតដើម្បីចាយវាយបណ្តោះអាសន្ន។ បន្ទាប់មកនៅថ្ងៃទី ២៩ មិថុនា ឆ្នាំ២០១៩ អ្នកបកប្រែ ក៏បានទូរស័ព្ទអោយនាងមកភ្នំពេញដើម្បីរៀបចំសម្រាលកូន។ នៅពេលស្ថិតនៅក្នុងរថយន្តធ្វើដំណើរទៅប្រទេសវៀតណាម នាងឃើញមានស្រ្តីចិន២នាក់ ទារកម្នាក់ ស្រ្តីខ្មែរម្នាក់ទៀតឈ្មោះ សាត សារួន ដែលឈ្មោះដាបញ្ជូនមកអោយមើលថែទាំទារកនិងអ្នកពពោះ។ ពេលធ្វើដំណើរទៅដល់ច្រកទ្វារបាវិតមានបុរសជនជាតិចិនម្នាក់ជាអ្នករត់ការចេញលុយកាក់ទាំងអស់។ បន្ទាប់មក

ពួកគេបានបន្តដំណើរតាមរថយន្តតាក់ស៊ីរហូតដល់ចំណតរថភ្លើងក្រុងហូជីមិញ និងបន្តដំណើរ២ថ្ងៃ២យប់ទើបដល់ទៅក្រុងហាណូយ។ ដល់ទីនោះមានជនជាតិចិនផ្សេងទៀត រៀបចំអោយបន្តដំណើរទៅព្រំដែន ក៏ត្រូវសមត្ថកិច្ចវៀតណាមចាប់ទាំងអស់គ្នាតែម្តង ដោយមានទាំងខ្មែរ ចិន វៀតណាមដែលរត់ការផង។ រហូតដល់ថ្ងៃទី ០៩កក្កដា ឆ្នាំ២០១៩ នៅពេលដែលវៀតណាម កំពុងឃុំខ្លួនបណ្តោះអាសន្នស្រាប់តែឈ្មោះ ភូន ស៊ីនឿនបាន ឈឺពោះសម្រាលបានកូនស្រីមួយ ហើយរហូតមកដល់ថ្ងៃទី ១៣កក្កដា ឆ្នាំ២០១៩ វៀតណាមសម្រេចបញ្ជូនស្រីៗមកប្រទេសកម្ពុជាវិញ ចំណែកជនជាតិចិន វៀតណាម និងខ្មែរ ដែលជាអ្នករត់ការត្រូវបានសមត្ថកិច្ចវៀតណាមចាត់កាងតាមច្បាប់របស់វៀតណាមនៅក្រុងហាណូយ។ រឿងក្តីពរពោះជំនួស ដែលក្រុមឈ្មួញមានគោលដៅនាំយកទារកទៅក្រៅប្រទេសនេះ អយ្យការអមតុលាការកំពុងសាកសួរជនសង្ស័យនៅឡើយ ដោយមិនទាន់កំណត់នូវបទល្មើស ដែលត្រូវចោទប្រកាន់នៅឡើយ៕

**ដោយ ៖ មករា**